ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៨ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ២៥២ អនក្រ.បក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការគ្រប់គ្រងការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល
- បានឃើញអនុក្រឹត្យលេខ១៦៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ស្តីពីការផ្លាស់ប្តូរទិន្នន័យ តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា
- យោងតាមការស្នើសុំរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះ កំណត់អំពីការធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម ដើម្បីធានាបាននូវប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសង្គតិភាពនៃការអនុវត្ត ក្នុងប្រព័ន្ធគាំពារសង្គមកម្ពុជា។

**មាត្រា ២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការចុះបញ្ជី និងផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណគាំពារសង្គម និងការធ្វើអន្តរប្រតិបត្តិការឌីជីថលតាមរយៈ ថ្នាលគាំពារសង្គមឌីជីថល សរសេរជាអក្សរកាត់ថា"**ថ.គ.ឌ.**" និងមូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម សរសេរជាអក្សរកាត់ថា"**ម.ទ.ច.ស.**" ក្នុងប្រព័ន្ធគាំពារសង្គមកម្ពុជា ដែលមានក្រសួង ស្ថាប័នពាក់ព័ន្ធដែលជាសមាជិកក្រុមប្រឹក្សាជាតិគាំពារសង្គម និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានកំណត់និយមន័យ ដូចខាងក្រោម÷

- **សុខដុមនីយកម្ម** សំដៅដល់ការកែសម្រួលភាពផ្សេងគ្នា និង/ឬភាពមិនស៊ីចង្វាក់គ្នាដែលពាក់ព័ន្ធនិងការវាស់វែង វិធីសាស្ត្រ នីតិវិធី កាលវិភាគ លក្ខណៈបច្ចេកទេស ឬប្រព័ន្ធដើម្បីធ្វើឱ្យមានឯកភាពមានភាពសមស្របសម្រាប់ទាំងអស់គ្នា។
- **អន្តរប្រតិបត្តិការ** សំដៅដល់សមត្ថភាពនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលអាចធ្វើសន្ទានកម្ម (ទៅវិញទៅមក) ជាមួយគ្នា ក្នុងការផ្លាស់ប្តូរ ប្រកបដោយប្រសិទ្ធភាព ដែលនឹងធ្វើឱ្យប្រសើរឡើងនូវគុណភាព ប្រសិទ្ធភាព និងភាពងាយស្រួលក្នុងការចូលទៅប្រើប្រាស់សេវាគាំពារសង្គមនានា ដោយអនុញ្ញាតឱ្យមានការទំនាក់ទំនង និងការផ្លាស់ប្តូរទិន្នន័យជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានាដោយងាយស្រួល និងដោយស្វ័យប្រវត្តិក្រោមលក្ខខណ្ឌច្បាស់លាស់។
- **ថ្នាលគាំពារសង្គមឌីជីថល** (Digital Social Protection Platform) ជាថ្នាលឌីជីថលរួមបែបសមាហរណរបស់រាជរដ្ឋាភិបាល ដំណើរការដោយតភ្ជាប់ជាមួយមូលដ្ឋានទិន្នន័យចុះបញ្ជីរបស់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ បង្កើតជាប្រព័ន្ធអន្តរប្រតិបត្តិការអេកូឡូស៊ីរួមសម្រាប់ប្រព័ន្ធគាំពារសង្គមកម្ពុជា។
- **មូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម** (Social Registry) ជាមូលដ្ឋានទិន្នន័យចុះបញ្ជីរួមបែបសមាហរណរបស់រាជរដ្ឋាភិបាល ផ្ទុកទិន្នន័យអត្តសញ្ញាណគាំពារសង្គម និងទិន្នន័យស្ថានភាពសង្គម-សេដ្ឋកិច្ច ដោយបង្កើតលេខសម្គាល់គាំពារសង្គមតែមួយគត់ចំនួន ១០ (ដប់) ខ្ទង់។
- **ទិន្នន័យអត្តសញ្ញាណគាំពារសង្គម** សំដៅដល់ទិន្នន័យនៃការកំណត់សម្គាល់ប្រជាជនគោលដៅដែលជាអត្ថគាហកក្នុងកម្មវិធីជំនួយសង្គម ឬរបបសន្តិសុខសង្គមណាមួយដែលដាក់ចេញដោយរាជរដ្ឋាភិបាល។
- **សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ** សំដៅដល់ច្រកចេញចូលនៃទំនាក់ទំនងក្នុងការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពីរឬច្រើន។
- **សមកាលកម្ម** (Synchronization) សំដៅដល់ការធ្វើបច្ចុប្បន្នកាលទីតាំងទិន្នន័យ ដែលនៅកន្លែងផ្សេងគ្នាឱ្យក្លាយជាមូលដ្ឋានទិន្នន័យតែមួយ ក្នុងខណៈតែមួយ។

## ជំពូកទី២
## ថ្នាលគាំពារសង្គមឌីជីថល និង មូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម

**មាត្រា ៤ .-**

**ថ.គ.ឌ.** ត្រូវបានបង្កើតឡើងដើម្បីបម្រើដល់ការចុះបញ្ជី ផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណគាំពារសង្គម និងផ្ទេរកញ្ចប់អត្ថប្រយោជន៍ និងសេវាគាំពារសង្គមនានា ដោយប្រើប្រាស់ថ្នាលឌីជីថលរួម ឈានទៅកាត់បន្ថយជាអតិបរមានូវប្រតិបត្តិការស្ទួន និងការបែកខ្ញែកនៃប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គមនៅកម្ពុជា។

**ម.ទ.ច.ស.** ត្រូវបានបង្កើតឡើងដើម្បីបម្រើឱ្យការកំណត់អត្តសញ្ញាណ ស្ថានភាពងាយរងគ្រោះ ស្ថានភាពងាយរងហានិភ័យ និងព័ត៌មានចុះបញ្ជីរបស់ប្រជាជនគោលដៅ សមាជិក និងអត្ថគាហកក្នុងកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ដែលទិន្នន័យទាំងនេះនឹងត្រូវចុះបញ្ជី ឬធ្វើសន្ទានកម្ម តាមរយៈ **ថ.គ.ឌ.** និងការធ្វើអន្តរប្រតិបត្តិការ និងសមកាលកម្មដោយប្រើប្រាស់ស្តង់ដាទិន្នន័យអត្តសញ្ញាណគាំពារសង្គមរួម ដែលត្រូវបានកំណត់ដោយ **ម.ទ.ច.ស.**។

**មាត្រា ៥ .-**

រាល់អន្តរប្រតិបត្តិការ និងសមកាលកម្មទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬប្រព័ន្ធចុះបញ្ជីរបស់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធជាមួយ **ថ.គ.ឌ.** និង **ម.ទ.ច.ស.** ត្រូវប្រើប្រាស់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា និងត្រូវធ្វើកំណត់ត្រាអេឡិចត្រូនិកនូវរាល់ប្រតិបត្តិការទាំងអស់ ដើម្បីធានាសុវត្ថិភាព សង្គតិភាព និងបរិយាបន្ននៃទិន្នន័យ។

ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ត្រូវធានាថាមិនមានការចែករំលែកទិន្នន័យអត្តសញ្ញាណគាំពារសង្គម និងទិន្នន័យស្ថានភាពសង្គម-សេដ្ឋកិច្ចជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយដោយគ្មានការអនុញ្ញាតពីម្ចាស់ទិន្នន័យដើមឡើយ។

## ជំពូកទី៣
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា ៦ .-**

ក្រុមប្រឹក្សាជាតិគាំពារសង្គម ជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដឹកនាំ និងគ្រប់គ្រង **ថ.គ.ឌ.** និង **ម.ទ.ច.ស.** សំដៅអនុវត្តការធ្វើសុខដុមនីយកម្ម និងឌីជីថលូបនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម ស្របតាមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៧ .-**

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម សរសេរជាអក្សរកាត់ថា "**អ.ក.គ.**" សម្របសម្រួលប្រតិបត្តិការរបស់ **ថ.គ.ឌ.** និង **ម.ទ.ច.ស.** ដោយសហការជាមួយគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធដែលជាសមាជិកក្រុមប្រឹក្សាជាតិគាំពារសង្គម និងស្នើនូវយន្តការស្ថាប័នសមស្រប ដើម្បីអនុវត្តប្រតិបត្តិការរបស់ **ថ.គ.ឌ.** និង **ម.ទ.ច.ស.** ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា ៨ .-**

**អ.ក.គ.** មានសមត្ថកិច្ចផ្ទៀងផ្ទាត់ រក្សាទុក គ្រប់គ្រង អភិវឌ្ឍ តភ្ជាប់ និងរក្សាសុវត្ថិភាពទិន្នន័យគាំពារសង្គម និងទិន្នន័យអត្តសញ្ញាណគាំពារសង្គម រួមមានទិន្នន័យប្រជាសាស្ត្រ និងទិន្នន័យជីវមាត្រ ដែលបានមកពីការចុះបញ្ជីលើ **ថ.គ.ឌ.** និងការធ្វើអន្តរប្រតិបត្តិការឌីជីថលរវាងមូលដ្ឋានទិន្នន័យរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង **ម.ធ.ច.ស.** ដែលទិន្នន័យអត្តសញ្ញាណគាំពារសង្គម ដែលបានចុះបញ្ជីរួចរាល់ ត្រូវផ្ទៀងផ្ទាត់ជាមួយប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន។

**អ.ក.គ.** មានសមត្ថកិច្ចត្រួតពិនិត្យគុណភាព សុវត្ថិភាព គណនេយ្យភាព តម្លាភាព និងសង្គតិភាពនៃទិន្នន័យគាំពារសង្គម ដែលអនុវត្តដោយស្ថាប័នប្រតិបត្តិករសន្តិសុខសង្គម និងជំនួយសង្គម។

**មាត្រា ៩ .-**

ក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលជាម្ចាស់ទិន្នន័យគាំពារសង្គម និងទិន្នន័យអត្តសញ្ញាណគាំពារសង្គម អាចអនុញ្ញាតឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធដែលជាសមាជិកក្រុមប្រឹក្សាជាតិគាំពារសង្គម ប្រើប្រាស់ និងផ្ទៀងផ្ទាត់ទិន្នន័យគាំពារសង្គម និងទិន្នន័យអត្តសញ្ញាណគាំពារសង្គមបាន ស្របតាមបែបបទ និងនីតិវិធី ដែលកំណត់ក្នុងអនុក្រឹត្យនេះ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

## ជំពូកទី៤
## មុខងារ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នអនុវត្តការធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម

**មាត្រា ១០ .-**

ក្រសួង ស្ថាប័នពាក់ព័ន្ធដែលជាសមាជិកក្រុមប្រឹក្សាជាតិគាំពារសង្គម និងរដ្ឋបាលថ្នាក់ក្រោមជាតិមានកាតព្វកិច្ចចូលរួមអនុវត្តការធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម។

**មាត្រា ១១ .-**

ក្រសួង ស្ថាប័នពាក់ព័ន្ធដែលជាសមាជិកក្រុមប្រឹក្សាជាតិគាំពារសង្គម និងរដ្ឋបាលថ្នាក់ក្រោមជាតិមានកាតព្វកិច្ចដូចតទៅ÷

- ប្រើប្រាស់ **ថ.គ.ឌ.** ក្នុងការចុះបញ្ជី និងធ្វើបច្ចុប្បន្នកម្មទិន្នន័យអត្តសញ្ញាណគាំពារសង្គមរួមសម្រាប់ការអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម
- ចូលរួមធ្វើសមកាលកម្មទិន្នន័យ និងប្រតិបត្តិការនៃប្រព័ន្ធចុះបញ្ជីដែលមានស្រាប់របស់ក្រសួង ស្ថាប័នសាមីជាមួយនឹង **ម.ធ.ច.ស.** ដើម្បីដំណើរការជាប្រព័ន្ធអេកូឡូស៊ីរួម
- ទទួលយក និងរក្សាទុកទិន្នន័យអត្តសញ្ញាណគាំពារសង្គម ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មក្នុង **ម.ធ.ច.ស.** និងលេខសម្គាល់គាំពារសង្គម ដែលនឹងត្រូវបានបង្កើតឡើង និងផ្តល់ជូនដោយ **ម.ធ.ច.ស.** ដើម្បីបម្រើដល់ការផ្ទៀងផ្ទាត់អត្តសញ្ញាណរួម និងធ្វើយថាភូតកម្ម
- ធ្វើការតភ្ជាប់ បញ្ជូន ផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នកម្មទិន្នន័យគាំពារសង្គម រួមមានទិន្នន័យប្រតិបត្តិការ ទិន្នន័យរដ្ឋបាល និងទិន្នន័យចុះបញ្ជីប្រជាជនគោលដៅ សមាជិក និងអត្ថគាហកនៃប្រព័ន្ធចុះបញ្ជីដែលមានស្រាប់ ជាមួយនឹង **ម.ធ.ច.ស.** ដោយគោរពតាមស្តង់ដា និងមាត្រដ្ឋានទិន្នន័យដែលបានកំណត់ដោយក្រុមប្រឹក្សាជាតិគាំពារសង្គម

- ប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រស្តង់ដា ដែលផ្តល់ដោយ **អ.ភ.គ.** ក្នុងការផ្លាស់ប្តូរផ្ទៀងផ្ទាត់ និងធ្វើអន្តរប្រតិបត្តិការឌីជីថលដោយប្រើប្រាស់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ជាថ្នាលផ្លាស់ប្តូរទិន្នន័យរួម
- ទទួលខុសត្រូវលើភាពត្រឹមត្រូវ ពេញលេញ និងគ្រប់ជ្រុងជ្រោយនៃទិន្នន័យអត្តសញ្ញាណដែលបានចុះបញ្ជី មុននឹងបញ្ជូនមកកាន់ **ម.ធ.ច.ស.**
- រាយការណ៍ជូនក្រុមប្រឹក្សាជាតិគាំពារសង្គម នូវរាល់ភាពមិនប្រក្រតី និងរៀបចំ និងរក្សាទុកនូវកំណត់ត្រាប្រតិបត្តិការ ក្នុងក្របខណ្ឌនៃការធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម ដើម្បីជាមូលដ្ឋានក្នុងការត្រួតពិនិត្យសន្តិសុខបច្ចេកវិទ្យាព័ត៌មាន និងបញ្ហាប្រឈមនានា និង
- សហការដោះស្រាយរាល់បញ្ហានានាពាក់ព័ន្ធនឹងការធ្វើអន្តរប្រតិបត្តិការឌីជីថលឱ្យបានឆាប់បំផុត និងចូលរួមផ្តល់កិច្ចសហការផ្សេងទៀតតាមការស្នើសុំរបស់ **អ.ភ.គ.**។

## ជំពូកទី៥
## គោលការណ៍នៃការប្រើប្រាស់ទិន្នន័យអត្តសញ្ញាណគាំពារសង្គម

**មាត្រា ១២ .-**

ក្រុមប្រឹក្សាជាតិគាំពារសង្គម ត្រូវធានាថារាល់ទិន្នន័យអត្តសញ្ញាណគាំពារសង្គម មានភាពត្រឹមត្រូវដែលអាចធ្វើជាប្រភពទិន្នន័យពិត និងមូលដ្ឋានក្នុងការផ្ទៀងផ្ទាត់អត្តសញ្ញាណគាំពារសង្គមក្នុងក្របខណ្ឌគាំពារសង្គមជាផ្លូវការបាន។

**អ.ភ.គ.** ត្រូវធ្វើការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណគាំពារសង្គមជាមួយនឹងទិន្នន័យអត្តសញ្ញាណបុគ្គលនៃប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន ដើម្បីធានាបាននូវសង្គតិភាព និងភាពត្រឹមត្រូវនៃទិន្នន័យ។

**មាត្រា ១៣ .-**

**អ.ភ.គ.** ផ្តល់លទ្ធភាពក្នុងការផ្ទៀងផ្ទាត់ និងធ្វើយថាភូតកម្មតាមរយៈសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រជូនក្រសួង ស្ថាប័នពាក់ព័ន្ធដែលជាសមាជិកក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីបម្រើដល់ការផ្តល់សេវាគាំពារសង្គម និងបើកកញ្ចប់អត្ថប្រយោជន៍នានា ឱ្យបានឆាប់រហ័ស ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

**មាត្រា ១៤ .-**

ក្រសួង ស្ថាប័នពាក់ព័ន្ធដែលជាសមាជិកនៃក្រុមប្រឹក្សាជាតិគាំពារសង្គមដែលមានបំណងប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រដើម្បីបម្រើដល់ការផ្ទៀងផ្ទាត់ និងការធ្វើយថាភូតកម្ម ត្រូវស្នើសុំការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ស្របទៅតាមបែបបទ នីតិវិធី និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការប្រើប្រាស់ទិន្នន័យអត្តសញ្ញាណគាំពារសង្គម ត្រូវធានានូវសុវត្ថិភាពទិន្នន័យ និងរក្សាការសម្ងាត់នៃឯកជនភាពបុគ្គល។

## ជំពូកទី៦
## ទណ្ឌកម្ម

**មាត្រា ១៥ .-**

បុគ្គល និងតួអង្គពាក់ព័ន្ធ ដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យ និងទោស ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

# ជំពូកទី៧
# អវសានប្បញ្ញត្តិ

**មាត្រា ១៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១១ កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ កុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ